# ច្បាប់ស្រី



និពន្ធដោយ បណ្ឌិត មីន មៃ ជា បទភុជង្គលីលា

# ច្បាប់ស្រី

នេះបទកំណាត់ចងជា ភុជង្គលីលា ចងជាច្បាប់ស្រី។
កាលនាងឥន្ទវតី ចរចាកតាមប្តី គឺបុណ្យកយក្សា។
នាងវិមលាជាព្រះមាតា បើកបន្ទូលថា ហៃកូនពិសី។
នាងនឹងត្រាច់ត្រង់តាមប្តី ចេញចាកអំពី ពិភពនាគនេះ។
ទៅឋានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បម្រើស្វាមី។
ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឲ្យស្វាមី អាក់អន់ចិន្តា។
នាងអើយគម្លែងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ។
ហៃកូនស្រីមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី។
ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឲ្យញាតិចូលចិត្ត។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងឆីស្លា។
ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រឡាញ់។
កុំជូចិត្តស្នូរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី។
ទោះនឹងនិយាយស្រដី ការកេរជាស្រី កុំស្តីឡេះឡោះ។
ថាលេងដូចក្មេងញ៉េះញ៉ោះ ឃើញប្រុសកម្លោះ សសៀរចូលជិត។
សើចព្រៀងកញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត វាហ៊ានដោយសារ។
ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន។
សើរើពុំធ្វើនឹងនួន ស្រដីមិនមូន មិនមានអៀនអន់។
ឃើញគេបៀតបៃរគយគន់ សើចស្ទូរចំអន់ ចំអកឲ្យប្រុស។
ហៅស្រីអប្រិយទុយ៉ស មិនខ្លាចខ្លួនខុស មារយាទក្រឹត្យក្រម។
ធ្វើការអង្គុយច្រឡំ នឹងសមពុំសម ថាឯងជាស្រី។
មិនកោតមិនខ្លាចចិត្តប្តី ឲ្យប្រុសដទៃ មាក់ងាយប្តីណា។
ហៅស្រីឥតលក្ខណា ឥតមានកិរិយា មារយាទពុំសម។
ធ្វើការផងណាប្រើខំ ទោះត្បាញចាក់ដំ នាងខំឲ្យហើយ។

# ច្បាប់ស្រី

កុំទុកទៅមុខទៀតឡើយ ថាចាំបង្អើយ កម្រណាស់ណា។
ទោះធ្វើហួលគោមព្រៃផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ។
ធ្វើឲ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឲ្យដើរ លេងផ្ទះគេណា។
ឱស្ងួនខ្លឹមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ។
មានប្ដីបានអ្វីជាខំ រវល់កូនយំ កម្រចេះឆ្លាត។
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត យំទារតែឆី។
រឹងព្រួយទាំងមួយទាំងពីរ រកបានឲ្យឆី ទើបបានបាត់មាត់។
ទៅកាន់ការធ្វើឲ្យស្ទាត់ ហួលគោមគាត់កាត់ អន្ទងត្បាញទៅ។
កុំទុកក្នុងស្មុគស្មាញនូវ ក្រែងដល់យូរទៅ ខាតខូចអសារ។
ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី។
ចូររករៀនយកច្បាប់ស្រី ឲ្យកោតខ្លាចប្ដី គម្ដែងក្រឡា។
ធ្វើវត្តប្រតិបត្តិសោតណា ឲ្យនាងរក្សា ភ្នក់ភ្លើងទាំងបី។
ឲ្យកាត់ឲ្យគង់ប្រក្រតី សព្វថ្ងៃកុំឲ្យបី ភ្លេចផ្លុំឲ្យឆេះ។
ក្រែងរាលដូចដាលព្រាយប្រេះ កើតក្ដៅរលេះ រលាយអស់អង្គ។
ភ្លើងក្រៅកុំនាំទៅក្នុង ឲ្យឆេះបំផ្លូង ឬផ្លុំបង្កាត់។
ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឲ្យឆេះឯក្រៅ។
អុជអាលបណ្ដាលឲ្យក្ដៅ ដាលដល់កូនចៅ អសោចអប្រិយ។
ឲ្យនាងខំប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឲ្យគង់។
ភ្លើងនោះឲ្យកូនពុំលង់ នឹងឲ្យឧត្ដុង ឧត្តមកន្លង។
កើតយសរបស់ទ្រព្យផង បរិបូរឥតហ្មង ប្រសើរក្ដាត់ណា។
ភ្លើងមួយនោះឲ្យរក្សា គឺគុណមាតា បិតាស្ងួនគ្រង។
ឲ្យនាងធ្វើដោយគន្លង ប្រណិប័តន៍កុំឆ្គង នឹងម្ដាយឪពុក។
ឲ្យខំថៃទាំញ៉ឹកញ៉ុក ចំណីចំណុក ចំណង់អាត្មា។
កុំឃ្លានទុកឆីឡើយណា ឆ្ងាញ់ឈ្ងុយពិសា ជូនជាប្រក្រតី។
ពាក្យពេចន៍ការកិច្ចអ្វីៗ អត់ឱនកុំបី ឲ្យអាក់ចិន្ដា។

# ច្បាប់ស្រី

ភ្លើងមួយគម្តែងក្រឡា គឺប្តីអាត្មា បិនថេររួមរ័ក្ស។
ឲ្យនាងប្រណិប័តន៍ជឿជាក់ កុំធ្វើឲ្យអាក់ ឲ្យអន់ចិត្តប្តី។
អត់ឱនខ្លាចខ្លួនជាស្រី កុំឲ្យស្រដី ទុកគេជាស្មើ។
ទោះកើតហេតុភេទសារពើ ពាក្យពុំប្រសើរ ជញ្ជឹងចាំស្តាប់។
ទោះប្តីស្រដីពុំគាប់ ពុំគួរឲ្យប្រាប់ បានដឹងដល់ម្តាយ។
កើតខឹងរែងរឹងខ្វល់ខ្វាយ ឮពាក្យពីម្តាយ ខ្សឹបខ្សៀវប្រាប់ប្តី។
មិនក្សាន្តបែកបានពីប្តី កើតជាសម្តី សួរចុះសួរឡើង។
ពុំស្ងាត់ស្ងៀមមាត់ចចើង ជជែកនាំឡើង ចចើងមិនបាត់។
តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀមឲ្យបាត់ ឲ្យបានទីសុខ។
ជជែកស្មើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់ឡើយនៃ។
នេះហៅភ្លក់ភ្លើងទាំងបី ម្តាយផ្តាំកូនស្រី ឲ្យខំរក្សា។
នាងគម្តែងក្រឡា ខុសឆ្គងម្តេចម្តា ម្តាយផ្តាំកូនស្រី។
ឲ្យអត់សង្កត់ហឫទ័យ កូនកុំស្រដី ដើមប្តីកំបាំង។
កុំជេរកុំចេញជាខ្លាំង ខ្សត់ខ្សោយខ្លៅខ្លាំង នាងកុំមើលងាយ។
លួងខ្សោយប្រើឲ្យនិយាយ ណែនាំលេងលាយ ឲ្យស្រួលវាចា។
ទោះប្តីស្រដីម្តេចម្តា ខេខឹងជេរថា បោះពាក្យទម្ងន់។
ក្រោធក្រេវផុលឆេវមិនអន់ មិនអាក់ស្រោកស្រន់ ដោយចិត្តគ្នាន់ក្នាញ់។
រអ៊ូរទាំទន្ទេញ ជេរថាជន្លេញ ត្បិតទាស់នឹងចិត្ត។
ឲ្យកូនស្រីស្ងួនខំអត់ ឲ្យបានរលត់ រលាយកំហឹង។
កុំកូនកាន់ខ្លួនប្រែប្រឹង តតបទៅនឹង អ្នកជាស្វាមី។
ខេខឹងក្រញឹងសម្តី មិនគិតខ្លួនស្រី ស្រដីទ្រគោះ។
ប្រកែកស្តីពាក្យគំរោះ គំរាមបញ្ជោះ បញ្ជោរឲ្យខឹង។
រឹងរូសមើលមុខសម្លឹង សម្លក់ទៅរឹង ចចឹងចង់ឈ្លោះ។
រឹងឆ្លូងឆ្លើយពាក្យបញ្ជោះ បំបែកជាឈ្លោះ បំបែរពុំទៀង។
ជេរថាឆ្កែឆ្មាបំព្រៀង ដៀលត្មះបញ្ឆៀង បញ្ឈឺចិត្តប្តី។

# ច្បាប់ស្រី

បោះបោកប្រទះអ្វីៗ ចាប់ចោលទៅដី បែកបាក់ពុំគិត។
មិនស្រួលទទួលបាត់មាត់ មួះម្នាក្នុងចិត្ត ឲ្យបានប្ដីចាញ់។
ទើបបានសុខចិត្តជាវិញ ហៅស្រីមួះម៉ួញ អាប់កេរ្តិ៍យសឆ្ងាយ។
ហៅកូនស្រីស្ងួនមាសម្ដាយ ខុសណាស់នាងអាយ កុំធ្វើដូចគេ។
ទោះបីបើប្ដីនាងជេរ នាងចូលទៅឯ ដំណេកគិតសិន។
ចេញមកនាងយកពាក្យទន់ ស្រដីឲ្យអន់ ស្រាយទោសនោះទៅ។
ទោះបីបើប្ដីប្រដៅ ចូរនាងចាំនៅ ទុកក្នុងអាត្មា។
ពាក្យពេចន៍កុំភ្លេចឡើយណា ក្រែងឆ្គងម្ដេងម្ដា ត្បិតបានផ្ដាំស្រាប់។
ព្រោះឯងមិនក្រែងមិនស្ដាប់ ពាក្យគេបង្គាប់ បង្កើតតែឈ្លោះ។
ឥតសុខអាក្រក់តែឈ្មោះ ឮគេប្រឈ្លោះ មិនចេះហៅល្ហែ។
នេះពុំរាប់ជាស្ត្រីទេ ជាអ្នកប៉ោឡែ ចិត្តចោរដកទង។
ឲ្យមាត់បង្ក្រាបប្ដីផង ឲ្យគេស្ដាប់ហោង ថាឯងគ្រាន់បើ។
គឺមោះនាងនោះមិនប្រើ មិនបើកឲ្យដើរ បញ្ចើឲ្យទេ។
ទោះបីប្ដីប្រើមាសមេ កុំកួនចំអែ ចំអៀកមិនទៅ។
ឆ្ងាយជិតកុំគិតរង់នៅ ក្រោកក្រេសដើរទៅ កុំឲ្យប្ដីជេរ។
កុំទៅនៅយូរផ្ទះគេ រវល់ទំនេរ រវៀសមកណា។
ហៃកូនខ្លឹមខ្លួនមាតា ជាស្រីនេះណា កម្រណាស់នាង។
មិនថាត្បិតល្អរូបរាង មិនរើសត្បិតជាង ចេះការទាំងគ្រប់។
មិនបានស្គាល់ទិគោរព ស្គាល់ទេឧបទ្រព ទាំងដប់ប្រការ។
ហៅតែនឹងល្អរូបា ពិតហើយចេះការ គួរកោតដោយយ៉ាង។
មួយរូបល្អសសន្លាង ឥតគេផ្ទឹមខាង ច្បាប់ផងមិនចេះ។
ល្អពិតគំនិតមិនជេះ ទោះខ្មៅក្រងេះ ការសោតសមគួរ។
គឺមោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់អស់ឥរិយា។
នេះឯងពីព្រេងលោកថា ហៅល្អរូបា កបកល្យាណី។
ហៃកូនស្រីស្ងួនពិសី ម្ដាយប្រាប់អំពី ឧបទ្រពចង្រៃ។

# ច្បាប់ស្រី

១០០. កាន់ក្បាលប្ដីហើយរកចៃ មិនបានលើកដៃ បិទទូលសំពះ។
លោកទុកស្មើកុកទំផ្ទះ រង្គំរង្គះ នឹងបង់អស់ទ្រព្យ។
កន្លងជើងប្ដីពុំគាប់ ព្រោះចិត្តចង់ឆាប់ រំលងជើងប្ដី។
ស្មើសត្វលលកស៊ីខ្មោចខ្មី ហើយច្រាលអប្រិយ កើតព្យាធិរោគា។
ចង្រៃមួយនៃរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង។
១០៥. ធ្វេសប្រាណខុសខានមិនរាំង មិនរុញបំបាំង មើលយល់សាយសុស។
ទុកស្មើគេអុជចន្លុះ ឲ្យចោរចូលផ្ទះ យកទ្រព្យទាំងឡាយ។
ស្រីមួយសើចលេងក្អាកក្អាយ ឮលេខចម្ងាយ រំលងផ្ទះបី។
ស្មើសត្វចចាតបក្សី ចូលភូមិផងក្ដី ចង្រៃក្លាត់ណា។
ស្រីមួយដេកដាក់កាយា ប្រះប្រែអាត្មា ឲ្យខ្នងទៅប្ដី។
១១០. ទុកស្មើពស់ក្រាយអប្រិយ ឡើងផ្ទះឥតបី ឥតបើគណនា។
ចង្រៃកាចក្រៃពុំជា នឹងព្រាត់ប្រាសគ្នា ពុំបានវែងឆ្ងាយ។
ស្រីមួយសក់វែងអន្លាយ រំសុសរំសាយ សក់សោតរេរា។
នៅមាត់អណ្ដូងមាត់ទ្វារ បីដូចមជ្ឈរា ឆ្មាលាក់ក្រចក។
ចង្រៃឥតបីបើរក រេរាសំកក មិនចុកសក់ងាយ។
១១៥. ស្រីមួយដើរទៅទាត់ជាយ ឮលាន់ស្មើរធ្លាយ ប្រចពីសន្ទឹក។
សំពត់ដាច់ដាចមិននឹក ដើរឮគគឹក ស្មើស្វូររន្ទះ។
ញាំញើសំណើរលះ ដាក់ជើងលើផ្ទះ គគ្រាំងគគ្រេង។
កក្រើកផ្ទះទាំងបីល្វែង ដូចកលគេសែង របស់ចេញទៅ។
ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្លងហួសទៅ មិនចាប់ចេញទុក។
១២០. ពុំចេរចំណេរទៅមុខ ពុំចេះដាក់ទុក រាយរាល់តែល្វែង។
ទ្រព្យនោះរលោះចេញឯង ចង្រៃទាស់ទែង ធ្វើឲ្យអន្តរាយ។
ទោះឆីចំណីនូវបាយ លបលូកកកាយ ពមពុំសណ្ដាប់។
កូនអើយនេះហើយចូរស្ដាប់ ហៅក្ដីឧបទ្រព ទាំងដប់ប្រការ។
ឲ្យចៀសអស់ទាំងនេះណា ឲ្យរៀនលក្ខណា ទាំងប្រាំពីរផង។

# ច្បាប់ស្រី

គឺព្រះមានបុណ្យកន្លង ទេសនាចែងចង ជាបទគាថា។
មួយមាតុមួយមិត្តភរិយា កាតុភរិយាជាតិ ទាសភរិយាផង។
ទាំងបួនប្រសើរឥតហ្មង គួរឲ្យចាំចង ទុកក្នុងអង្គា។
រីឯហៅមាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្តាយ។
ចរិតបីប្រការក្នុងកាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍ឲ្យប្តី។
បានថ្កើងរុងរឿងពួល្បី មិនឲ្យអាប់ប្តី ឲ្យបានសក្តិយស។
មួយបើប្តីស្លៀកពាក់ចាស់ យកថ្មីឲ្យផ្លាស់ ចាស់ស្លៀកខ្លួនឯង។
ចេះរៀបរណ្តាប់តាក់តែង ចំណីផងស្ងែង រកមកឲ្យប្តី។
មួយបើប្តីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្តី រកថ្នាំសង្កូវ។
រកពេទ្យមេមត់នូវគ្រូ គ្រោះយាមគន់គូរ មើលប្តីឲ្យជា។
រីឯហៅកាតុភរិយា ប្រសើរសោភា ប្រពន្ធស្មើបង។
នោះមានចរិតពីរផង ដូចប្អូននិងបង ចិត្តមូលមួយប្រាណ។
មួយធ្វើឲ្យប្តីក្សេមក្សាន្ត របស់ប្តីបាន ចេះទុករក្សា។
មួយទោះឮពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្តី។
ពុំត្រូវអាស្រូវអប្រិយ ចេះការកេរ្តិ៍ប្តី បែរបានជាសុខ។
ទោះបីបើប្តីមានទុក្ខ គិតឲ្យបានសុខ យកខ្លួនធានា។
មួយសោតឯមិត្តភរិយា មានចរិតជា បីប្រការមិញ។
បីដូចកលមិត្តសម្លាញ់ មានចិត្តអស់អញ មិនឲ្យមានហ្មង។
បីដូចកលប្អូននិងបង ប្រាសយូរលង់ហោង ទើបមកជួបគ្នា។
មានចិត្តប្រតិព័ទ្ធមហិមា ត្បិតបានជួបគ្នា មិនឲ្យមានហ្មង។
មួយមានមារយាទកន្លង ទោះឃើញប្រុសផង មិនល្មៀងចិត្តទៅ។
រីទាសភរិយានោះក្ងូវ ក្នុងមាត្រាត្រូវ ប្រពន្ធខ្ញុំប្តី។
ចរិតប្រាំបីប្រការខ្មី មួយចិត្តខ្លាចប្តី ក្រែងប្តីវាយជេរ។
ប្រុងចិត្តការគិតខ្មាសគេ មិនឲ្យប្តីជេរ បន្ទោសខ្លួនបាន។
ទោះខឹងប្តីក្រែប៉ុន្មាន មិនចេះហៅហាន ឆ្លើយឈ្លោះតមាត់។

# ច្បាប់ស្រី

១៥០. មួយទោះប្ដីនោះកាចក្លាត់ ខឹងដល់វាយវាត់ ជេរចោរដកទង។
មិនហ៊ានឆ្លើយឈ្លោះរំលង តតបទៅផង ក្រែងព្រកេរ្តិ៍ឆ្ងាយ។
មួយចេះប្រដាប់រៀបបាយ ប្ដីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ។
អត់ចាំទម្រាំប្ដីមក ជួបជុំទើបយក បរិភោគផងគ្នា។
នេះឯងហៅទាសភរិយា សម្ដេចភគវា ទេសនាប្រោសប្រាប់។
១៥៥. បើអស់ស្រីណាបានស្ដាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ។
លុះអស់អាយុក្សិណក្ស័យ បានទៅកើតឰ តុសិតសួគ៌នាយ។
នឹងបានក្សេមក្សាន្តពណ្ណរាយ សេពសុខសប្បាយ និរទុក្ខកយា។
រីឯប្រពន្ធពុំជា ពេជ្ឈឃាតភរិយា ចរិតមានបួន។
កុំឲ្យយកទុក្ខក្នុងខ្លួន ឲ្យចៀសចេញជួន កើតកម្មវេរា។
១៦០. មួយចិត្តគំនិតចង់ជា ឆ្លាស់ឆ្លើយបំពារ បំពានឲ្យប្ដី។
ប្រទូសរឹងរូសខ្ញូវខ្ញី មិនចេះចាញ់ប្ដី ថាឯងគ្រាន់បើ។
ឆ្លើយឆ្លងសូរសងបណ្ដើរ ចង់ឈ្លោះឲ្យស្មើ ឲ្យលើសប្ដីវិញ។
មួយមិនចង់ធ្វើបំពេញ បង្គាប់ប្ដីវិញ ឲ្យធ្វើងខ្លួនឯង។
អាងចេះដៀលតិះពុំក្រែង ឲ្យប្ដីស្ដាប់ឯង ដោយចិត្តអន្ធពាល។
១៦៥. មួយមានចិត្តនោះស្រើបស្រាល ចង់ត្រេកត្រអាល ចោលពេញមុខប្ដី។
មួយចិត្តទ្រើស្តិទ្រស្តអប្រិយ ចង់សម្លាប់ប្ដី ស្រឡាញ់ប្រុសទៀត។
គិតកាប់សម្លាប់បង់មៀត នឹងយកប្រុសទៀត ធ្វើប្ដីមរណា។
រីឯសត្រូវភរិយា ចរិតពុំជា ប្រាំពីរប្រការ។
មួយមិនខ្លាចប្ដីអាត្មា បង្គាប់ត្រង់ណា ពុំធ្វើតាមចិត្ត។
១៧០. មួយទ្រឹងទ្រមឹងស្ងៀមស្ងាត់ ប្ដីសួរបីម៉ាត់ ពុំស្រដីផង។
មួយប្ដីស្រដីគន្លង ប្រដៅច្បាប់ផង ពុំចូលចិត្តស្ដាប់។
មួយមិនចង់ឲ្យប្ដីគាប់ មិនចង់ប្រដាប់ ឲ្យប្ដីថ្កុំថ្កើង។
មួយទោះនឹងស្រដីឡើង ពាក្យធំចចើង ចចេសនឹងប្ដី។
មួយទោះប្ដីលោះខ្ញុំស្រី វាបម្រើប្ដី មិនឲ្យអាក់អន់។

# ច្បាប់ស្រី

១៧៥. ឃើញគាប់រឹងស្អប់ក្នាញ់គ្នាន់ ក្នុងចិត្តប្រច័ណ្ឌ ជេរថានាយអាយ។
មួយត្បិតប្ដីមានសាហាយ ហួរហែកសុសសាយ ឲ្យប្ដីអាស្រូវ។
រីចោរភរិយានោះកូវ ចរិតពុំត្រូវ មានបីប្រការ។
មួយចង់ចាយទ្រព្យប្ដីណា ឲ្យខូចអសារ មិនគង់ជាល្អ។
មួយប្ដីឃ្នាតខ្ទីខំរក របស់បានមក មិនថែទាំទុក។
១៨០. លួចឲ្យទៅម្ដាយឪពុក ប្ដីសួររកមុខ មិនប្រាប់ឡើយណា។
មួយខ្ជិលមិនចង់ធ្វើការ កុហកមុសា ថាឯងរវល់។
ដេកលេងចំខែងអស់កល លុះប្ដីគេយល់ ពុតធ្វើជាឈឺ។
ទទូរដេកថ្ងូរហ៊ឺៗ ប្ដីហៅមិនឮ ពុតចង់តែស្លាប់។
នេះហៅប្រពន្ធពុំគាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ។
១៨៥. លុះអស់អាយុក្ស័យក្លាយ ធ្លាក់ទៅអបាយ ទាំងបួនចំពូក។
តែងនឹងរងទុក្ខរងសោក រំដោះរួចមក កើតជាមនុស្សខ្ទើយ។
ហេតុអកុសលនេះហើយ ត្បិតខ្លួនឥតត្រើយ ធ្វើខុសគន្លង។
ខុសវត្តប្រតិបត្តិឆ្គាំឆ្គង មិនវៀងមិនរង ខុសនឹងច្បាប់ស្រី។
មាក់ងាយនោះមានប្រាំបី មានក្នុងបាលី ព្រះធមិលោកថា។
១៩០. មាក់ងាយមួយនោះឯងណា ត្បិតប្ដីពិការ មិនបានមាំមួន។
ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ គ្រូគ្រោះមេមត់។
មើលប្ដីឲ្យជាឆាប់ផុត ខឹងវិញមិនអត់ បន់ឲ្យប្ដីស្លាប់។
មាក់ងាយមួយប្ដីខ្សត់ទ្រព្យ គ្មានកេរកោះគាប់ ស្មើនឹងអាត្មា។
ដៀលត្មះថាច្រាសដោយសារ ព្រោះខ្ជិលធ្វើការ ទើបគ្មានរបស់។
១៩៥. មាក់ងាយត្បិតប្ដីអប្បយស ឯងត្រកូលខ្ពស់ ពូជពង្សពុំស្មើ។
ឆ្មើងខ្លួនឲ្យប្ដីបម្រើ ឈ្លោះឡើងហើយដើរ ដៀលត្មះពូជពង្ស។
មាក់ងាយមួយត្បិតប្ដីល្ងង់ ខ្លៅខ្លួនទ្រមង់ ទ្រមក់យឺតយូរ។
ដៀលត្មះពុំចេះអាសូរ សម្ដីខ្មោះខ្មូរ មិនក្រែងប៉ុនសក់។
មាក់ងាយមួយប្ដីអាក្រក់ សាច់ខ្មៅប៉ប៉ក់ មុខអុតស៊ីសុស។

# ច្បាប់ស្រី

២០០. កន្ទ្រល រោងរលក្រអុះ សក់ស្កាញស្កូវសុស ពោះធំប៉ុនពាង។
ខ្លួនឯងចិញ្ចែងរូបរាង ខ្លួនសល្អជាង ថាប្ដីមិនសម។
មាក់ងាយមួយប្ដីមិនខំ ធ្វើការលេលាំ ឡែឡឡដើរលេង។
ឆ្លៀតឆ្លើយបោះពាក្យគគ្រេង ឈ្លោះជេរមិនឈ្វេង គិតខុសមាត្រា។
មាក់ងាយមួយប្ដីផឹកស្រា ស្រវឹងចោលការ ដើរលេងតែតោ។
២០៥. ពាក្យក្អេងរាំច្រៀងឡោៗ ឲ្យឆ្អែព្រុសឆោ ផ្ដើលភ្ញាក់កូនចៅ។
ឮមាត់ប្ដីហើយខឹងក្ដៅ ប្រទេចជេរទៅ តាមដោយចិត្តក្នាញ់។
មាក់ងាយមួយទៀតនោះមិញ ត្បិតប្ដីស្រឡាញ់ លលូកប្រឡែង។
មួលបិចចាក់ចុចជាល្បែង មិនមានកោតក្រែង បានចិត្តជេរវិញ។
ត្បិតតែយល់គេស្រឡាញ់ ស្រដីផងមិញ គំរោះគំរើយ។
២១០. ធ្វើក្នាញ់បែរចេញព្រងើយ គេនឹងកន្តើយ ក្ដិចក្នក់មាយា។
ពុំបានក្សេមក្សាន្តនឹងគ្នា មាក់ងាយនេះជា គំរប់ប្រាំពីរ។
កូនអើយនេះហើយច្បាប់ស្រី ឲ្យកូនពិសី រករៀនរក្សា។
យកទុកក្នុងអង្គអាត្មា ប្រសើរក្ដាត់ណា កើតសុខសួស្ដី។
ប្រសើរទាំងនាលោកិយ ទោះបរលោកក្ដី សឹងលុះប្រាថ្នា។
២១៥. ទោះចិត្តគន់គិតសទ្ធា ជាពុទ្ធមាតា សឹងបានបរិបូរណ៍។
ដូចចិត្តផុតឆាប់ពុំយូរ កបកើតសម្បូរ សម្បត្តិទ្រព្យផង។
កើតយសខ្ពង់ខ្ពស់កន្លង យឺនយូរឥតហ្មង ដូចក្ដីប្រាថ្នា។
ច្បាប់នេះឧត្ដមថ្លៃថ្លា ទោះស្រីឯណា ឮហើយមានភ័ព្វ។
ជាល្អកម្របានស្ដាប់ ស្ដាប់ហើយចូរចាប់ ចូរចាំគ្រប់គ្នា។
២២០. បានដល់មគ្គផលសួគ៌ា ប្រសើរសោភា ចូរចាំកុំភ្លេច។
ចរចាអស់អាថិពាក្យពេចន៍ ពាក្យពិតកាព្យកិច្ច បរិបូរណ៍ប្រពៃ។
ប្រាជ្ញាប្រែរឹងនាមនៃ ខ្ញុំឈ្មោះម៉ឺន មៃ មែនមានសទ្ធា។
មានចិត្តក្ខួចគិតកាព្យា កបកើតជ្រះថ្លា ត្រេកត្រង់កុសល។
សទ្ធាប្រាថ្នាមគ្គផល ផុរផុសយោបល់ លេចលើកទុកនៅ។

# ច្បាប់ស្រី

២២៥. ទោះបីសេចក្ដីខុសត្រូវ សូមទានតម្រូវ តម្រង់ឲ្យផង។
កុំត្មះតិះដៀលឡើយហោង សូមសាងផលផង ទុកតសាសនា។
សម្រាប់ជាច្បាប់មាត្រា សូរេចបការា បរិបូរណ៍ថែងចប់៕


បានទទួលឧបត្ថម្ភ ពី **មូលនិធិខ្មែរសំរាប់ការសិក្សា**

បានចម្លង ជា e book ដោយ ហិន គិមឈិន

សីហា ២០១២